**ផលប្រយោជន៍ដ៏លើសលុបនៃឧស្សាហកម្មច្នៃប្រតិដ្ឋ**

**ចំណុចសំខាន់ខ្លីៗ៖**

- ឧស្សាហកម្មច្នៃប្រតិដ្ឋជាឧស្សាហកម្មដ៏មានសក្តានុពលខ្ពស់បំផុតមួយ ដែលរដ្ឋាភិបាលជាច្រើននៅជុំវិញពិភពលោកកំពុងដាក់ ឧស្សាហកម្មច្នៃប្រតិដ្ឋ ជាគោលនយោបាយយុទ្ធសាស្ត្រ និងអទិភាព ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់គេ។
- នៅទូទាំងសាកលលោក ឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋ ទាញប្រាក់ចំណូលសរុបប្រចាំឆ្នាំប្រមាណ US$2.250 កោដិដុល្លារ និងនាំចេញច្រើនជាង US$250 កោដិដុល្លារសហរដ្ឋអាមេរិក។
- ឧស្សាហកម្មច្នៃប្រតិដ្ឋមានសារៈសំខាន់ខ្លាំងចំពោះសេដ្ឋកិច្ចនៃប្រទេសជាច្រើន និងបានផ្តល់ការងារចំនួនដ៏ច្រើនលើសលប់នៃប្រជាជន (ឧទាហរណ៍ ឧស្សាហកម្មច្នៃប្រតិដ្ឋ ផ្តល់ការងារ 2.3 លានការងារ ដល់ប្រជាជនអង់គ្លេស (ប្រជាជនសរុប 67 លាននាក់)
- ក្រៅពីផលប្រយោជន៍ដ៏ច្រើនមកលើសេដ្ឋកិច្ច គេត្រូវគិតអំពីគុណតម្លៃសង្គម និងវប្បធម៌នៃឧស្សាហកម្មច្នៃប្រតិដ្ឋផងដែរ និងគួរតែគិតគូរ បង្ការ និងកាត់បន្ថយផលប៉ះពាល់នៃឧស្សាហកម្មច្នៃប្រតិដ្ឋមកលើបរិស្ថាន។

ក្នុងអំឡុងពេលមួយទសវត្សចុងក្រោយនេះ រដ្ឋាភិបាលមួយចំនួននៅជុំវិញពិភពលោកបានទទួលស្គាល់ ហើយបានចាប់ផ្តើមបង្កើតគោលនយោបាយជាក់លាក់ដើម្បីលើកកម្ពស់វិស័យនេះ។ វិស័យច្នៃប្រតិដ្ឋ ដែលពីមុនមិនសូវមានគេចាប់អារម្មណ៍តិចតួចពីអ្នកស្រាវជ្រាវ បានប្រែក្លាយជាវិស័យរីកចម្រើន និងបានជំរុញឱ្យអ្នកស្រាវជ្រាវត្រូវសិក្សា វិភាគ និងសិក្សាអំពីទំនាក់ទំនងរវាងវប្បធម៌ ឧស្សាហកម្មច្នៃប្រឌិត និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងដើម្បីបង្កើតគោលនយោបាយ។ ទោះជាយ៉ាងណាក៏ដោយ វិស័យនេះនៅតែមានគេយល់តិចតួច ហើយរដ្ឋាភិបាលជាច្រើននៅតែមិនទាន់យល់ និងត្រូវការឱ្យមានការបញ្ជាក់ពន្យល់ប្រាប់ពីសក្តានុពលរបស់វា ខណៈដែលវិស័យដ៏មានសក្តានុពលនេះនៅមានបញ្ហាប្រឈមជាច្រើនដទៃទៀត។ (១)

បើយោងតាមទិន្នន័យសូចនាករវប្បធម៌ដើម្បីអភិវឌ្ឍ ចេញដោយអង្គការយូណាស្កូ (២០១៨) នៅឆ្នាំ ២០១១ ឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋនៃកម្ពុជា បានផ្តល់ផលប្រមាណ 1.53% នៃទិន្នផលសរុបក្នុងស្រុក (ជាមធ្យម នៅអាស៊ាន គឺប្រមាណជា 5-7%) ខណៈដែលនៅទូទាំងសាកលលោក ឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋ ទាញប្រាក់ចំណូលសរុបប្រចាំឆ្នាំប្រមាណ US$2.250 billion និងនាំចេញច្រើនជាង US$250 កោដិដុល្លារសហរដ្ឋអាមេរិក។ (២)

បើយោងតាមគេហទំព័រ The ASEAN Post ឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋនៃប្រទេសឥណ្ឌូនេស៊ីបានចូលរួមចំណែក 7.4% នៃទិន្នផលសរុបប្រចាំឆ្នាំ។ រូបខាងក្រោមបង្ហាញអំពីការចូលរួមចំណែកពីវិស័យទាំង ១៦ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺ វិស័យបោះពុម្ពជាវិស័យចូលរួមចំណែកខ្ពស់មួយ (៦.១៨%) បើប្រៀបធៀបនឹង
វិស័យធំៗជាច្រើនទៀតដូចជា ភាពយន្ត (0.48%) និងតន្ត្រី (0.49%) ជាដើម។ (៣)




អ្នកបង្កើតគោលនយោបាយកាន់តែច្រើនផ្តោតការយកចិត្តទុកដាក់មកលើឧស្សាហកម្មច្នៃប្រតិដ្ឋ។ តែទោះជាយ៉ាងណា មានមតិជាច្រើនដែលជឿថា គេមិនគួរផ្តោតលើតែគុណតម្លៃសេដ្ឋកិច្ច ដោយផ្តាច់ចេញ ឬមិនគិតគូរចាប់អារម្មណ៍លើគុណតម្លៃសង្គម និងវប្បធម៌របស់វិស័យនេះនោះទេ។ ការស្ទង់មតិរបស់អង្គការសហប្រជាជាតិស្តីពីសេដ្ឋកិច្ចច្នៃប្រឌិតពិភពលោកដែលត្រូវបានបោះពុម្ពក្នុងឆ្នាំ 2008 បានចង្អុលបង្ហាញថា ឧស្សាហកម្មច្នៃប្រតិដ្ឋ មិនត្រឹមតែជា "ចំណុចប្រសព្វរវាងការច្នៃប្រឌិត វប្បធម៌ សេដ្ឋកិច្ច និងបច្ចេកវិទ្យា និងសក្តានុពលក្នុងការបង្កើតប្រាក់ចំណូល ការងារ និងការនាំចេញប៉ុណ្ណោះទេ ស្របពេលជាមួយគ្នានេះ ឧស្សាហកម្មច្នៃប្រតិដ្ឋ ក៏ចូលរួមចំណែក និងដើរតួនាទីសកម្មក្នុងការលើកកម្ពស់ការរួមបញ្ចូលក្នុងសង្គម ភាពចម្រុះនៃវប្បធម៌ និងការអភិវឌ្ឍរួមផងដែរ។ បញ្ហាសំខាន់មួយទៀតគឺ ឧស្សាហកម្មច្នៃប្រតិដ្ឋ និងបរិស្ថាន ដែលគេទាមទារឱ្យមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ខ្ពស់ ដើម្បីបង្ការ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃឧស្សាហកម្មច្នៃប្រតិដ្ឋមកលើបរិស្ថាន។ (៥)

អានបន្ថែម៖


១) UNESCO | Europa Regina

២) https://en.unesco.org/creativity/news/cambodia-binding-culture-economic-development

៣) https://theaseanpost.com/article/getting-creative-indonesia

៤) https://creativeconomy.britishcouncil.org/guide/what-creative-economy/

៥) Creative Industries and the Climate Emergency: The Path to Net Zero (culturehive.co.uk)